**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី៤

## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៦៦ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣

## សម្រាប់លោក ពាន សុខាឡៃ ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារព្រែកអញ្ចាញ

## ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល

## សម្រាប់ការពង្រីកតំបន់ចែកចាយ

DECISION ON FOURTH REVISION

OF THE CONSOLIDATED LICENSE DOCUMENT N° 066 LD DATED NOVEMBER 20, 2003

FOR MR. **PEAN SOKHALAY** FOR PROVIDING ELECTRICITY SERVICES AT PHSAR

PREK ANH CHAGN, KHUM PREK ANH CHAGN, MUKOMPUL DISTRICT,

KANDAL PROVINCE

FOR EXTENDING DISTRIBUTION AREA

**ថ្ងៃទី... ខែ... ឆ្នាំ២០០៩**

**..., 2009**

**ព្រះរាជាណាចក្រកម្ពុជា**
KINGDOM OF CAMBODIA
**ជាតិ សាសនា ព្រះមហាក្សត្រ**
NATION RELIGION KING

**អាជ្ញាធរអគ្គិសនីកម្ពុជា**
ELECTRICITY AUTHORITY OF CAMBODIA

លេខ : -០៩-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៤
## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៦៦ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣
## សម្រាប់លោក ពាន សុខាឡៃ

# DECISION ON FOURTH REVISION
## TO THE LICENSE DOCUMENT N° 066 LD DATED NOVEMBER 20, 2003
## FOR MR. PEAN SOKHALAY

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03, dated 02/02/2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៦៦ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣

- In accordance with License Documents N°066 LD dated November 20, 2003.

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក ពាន សុខាឡៃ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩

- In accordance with the application for extending distribution area of Mr. PEAN SOKHALAY dated July 9, 2009.

-យោងរបាយការណ៍របស់នាយកដ្ឋានបញ្ញត្តិកម្មអគ្គិសនី ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩

- In accordance with the report of Department of Electric Regulation dated July 21, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩

- In accordance with the consultation with concerned parties and public, made from ..., 2009 to ..., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី... នៅថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia's Session N°..., dated ..., 2009

.

# សម្រេច

# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលអាជ្ញាប័ណ្ណលេខ០៦៦ អ ដែលបានផ្តល់ឱ្យលោក **ពាន សុខាឡៃ** ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅទីប្រជុំជនផ្សារព្រែកអញ្ចាញ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនី ដែលមានស្រាប់ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១កែសម្រួលថ្មី ។ | **Article 1**<br>To revise License N° 021 L granted to Mr. Pean Sokhalay to supply electric power at Phsar Prek Anh Chagn, Khum Prek Anh Chagn, Mukompul District, Kandal Province to give the right to licensee to extend the existing distribution area as show in the attached map in new revised schedule 1. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ០៦៦ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents Nº 066 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃអាជ្ញាប័ណ្ណលេខ ០៦៦ អ ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents Nº 066 LD. |
| **ប្រការ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៦៦ឯអ និងខ្លឹមសារដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។ | . **Article 4**<br>The other contents and conditions of the license document Nº 066 LD with its revisions shall remain in force. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article5**<br>The decision shall come into force from the date of signing. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើរសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៦៦ ឯអ ដែលបានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៦៦ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document Nº 066 LD has been deposited in order that the deposited license document Nº 066 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ..., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF EAC

# ឧបសម្ព័ន្ធទី១

## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº... DATED ..., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោក ពាន សុខាឡៃ ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺ ទីប្រជុំជនផ្សារព្រែកអញ្ចាញ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ។ | 1. The authorized distribution Areas, where Mr. Pean Sokhalay has the right to provide the electricity distribution and supply services at Phsar Prek Anh Chagn, Khum Prek Anh Chagn, Mukompul District, Kandal Province |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 066LD-map-Pean Sokhalay-Revision4-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is determined by the boundary map 066LD-map-Pean Sokhalay-Revision4-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ពាន សុខាឡៃ មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះ លោក ពាន សុខាឡៃ ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមក អាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្ដីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mr. Pean Sokhalay intends to request the extension or the additional distribution areas then Mr. Pean Sokhalay shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |